# ការប្តេជ្ញាចិត្តបំរើនៅក្នុងក្រុមជំនុំ



ការប្តេជ្ញាចិត្ត ជាពាក្យដែលគេមិនសូមចូលចិត្តយកមកប្រើប៉ុន្មានទេ នាពេលបច្ចុប្បន្ននេះ។ លោកអ្នកក៏បានឃើញដែរថា នេះជាកង្វះខាតនៅក្នុងចំណោមកុមារមួយចំនួនដែលមិនស្តាប់បង្គាប់ឪពុកម្តាយ និងគ្រូបង្រៀននៅឯសាលារៀនរបស់ពួកគេ។ ក៏មាននៅកន្លែងធ្វើការ ក្នុងចំណោមមនុស្សពេញវ័យ និងតាមបណ្តាវិស័យនានាជាច្រើនទៀតនៅក្នុងសង្គម។ ទំនាក់ទំនងមានភាពតានតឹង ដែលជារឿយៗនាំឲ្យមានការបាត់បង់នូវទំនុកចិត្ត ។ ជាអកុសល សូម្បីតែគ្រិស្តបរិស័ទជួនកាលក៏ថ្លោះធ្លោយនៅក្នុងទង្វើរដែលមិនត្រឹមត្រូវនោះដែរ។ ដូច្នោះហើយ ពួកគាត់បានហក់ពីក្រុមជំនុំមួយទៅក្រុមជំនុំមួយទៀត ដោយនាំយកបញ្ហាដែលមិនទាន់បានដោះស្រាយទៅជាមួយ។ ការនោះមិនគួរឲ្យកើតមានឡើងឡើយ ។

ម៉្យាងវិញទៀត ជាការប្រពៃយ៉ាងណាទៅ ដែលបានចូលរួមជាមួយក្រុមមនុស្សដែលមានការប្តេជ្ញាចិត្ត ចេះយកអាសាគ្នា គាំទ្រគ្នា ដែលជាអ្នកដែលផ្សាភ្ជាប់ដោយក្តីស្រឡាញ់រួមមកតែមួយរវាងគ្នានឹងគ្នា។ ក្រុមជំនុំ៖ «ការហៅមករួមគ្នាតែមួយ» គួរតែមានលក្ខណៈដូច្នោះ ។



ក្រុមជំនុំមិនមែនជាអាគារនោះទេ ប៉ុន្តែជាកន្លែងដែលមានអ្នកជឿជួបជុំគ្នា។ ដូច្នេះក្រុមជំនុំអាចមាននៅតាមផ្ទះ នៅតាមទីវាលមានខ្យល់អាកាស ឬកន្លែងដែលមានអាគារដែលយើងស្គាល់ថាជាព្រះវិហារ។ ក្រុមជំនុំដែលខ្ញុំថ្វាយបង្គំ (ក្នុងពេលកំពុងសរសេរ) ធ្វើការជួបជុំគ្នានៅតាមសាលប្រជុំក្នុងទីក្រុងដែលត្រូវជួលសម្រាប់តែពេលជួបជុំគ្នាប៉ុណ្ណោះ ។

ក្រុមជំនុំ ដែលគេបានស្គាល់នៅក្នុងគម្ពីរសញ្ញាថ្មីដែលហៅថាជា 'គ្រួសារ' នៃព្រះ អេភេសូរ២:១៩។ សមាជិកនៃគ្រួសារនេះ គឺជាពួកអ្នកជឿ (ឬពួកបរិសុទ្ធ) ពួកបរិសុទ្ធមានន័យថា មនុស្សដែលបានញែកចេញនៅចំពោះព្រះជាម្ចាស់។ ដូច្នេះ មុខងារនៃក្រុមជំនុំគឺស្រដៀងគ្នាទៅនឹងគ្រួសារមួយ ។ អ្វីដែលជាភាពខុសគ្នានោះ គឺព្រះគ្រិស្តជាសិរសារនៃគ្រួសាររបស់ព្រះអង្គ អេភេសូរ៥:២៣។

## ការរំពឹងទុករបស់សមាជិកគ្រួសារ

### ១. សេចក្តីស្រឡាញ់

ការប្តេជ្ញាចិត្តរបស់ក្រុមជំនុំ គឺផ្អែកលើទំនាក់ទំនង មិនមែនគ្រាន់តែជាការចូលរួមនៅក្នុងក្រុមជំនុំប៉ុណ្ណោះទេ។ ជាអ្វីដែលអាចធ្វើទៅបាននៅក្នុង ការចុះកិច្ចព្រមព្រៀង ហើយក្លាយជាសមាជិកនៃក្រុមជំនុំមួយ ប៉ុន្តែប្រសិនជាមិនមានទំនាក់ទំនងល្អទេនោះ ការចូលជាសមាជិកប្រភេទនេះនឹងក្លាយទៅជារឿងដែលគួរឲ្យអស់សំណើយរិញ។ ម៉្យាងទៀត ទិដ្ឋភាពដែលគួរអោយចាប់អារម្មណ៍នោះ គឺការដែលឃើញមនុស្សចេះយកអាសាគ្នា ទោះជានៅក្នុងផ្ទះ និងក្នុងពេលដែលមានស្ថានភាពអ្វីមួយកើតឡើងក៏ដោយ ។

*ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំអោយបទបញ្ញាថ្មីដល់អ្នករាល់គ្នា*

*គឺត្រូវ ស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ»* ។

សូមអាន យ៉ូហាន ១៣:៣៤ ។
ពិភាក្សា និងសរសេរចុះពីការអនុវត្តជាក់ស្តែង នៃសេចក្តីស្រឡាញ់នេះ ។

---

## ២. គោរពចុះចូល ចំពោះសិទ្ធិអំណាច

ការប្តេជ្ញាចិត្តក្នុងគ្រួសារមានន័យថា ត្រូវតែមានការគោរពចុះចូលចំពោះសិទ្ធិអំណាច នៅក្នុងរចនាសម្ព័ន្ធគ្រួសារនោះ។ យើងត្រូវគោរពចុះចូលគ្នាទៅវិញទៅមក (ភីលីព ២:៣-៤) ប៉ុន្តែការទទួលខុសត្រូវចុងក្រោយ គឺជាក្រុមជំនុំដែលមានភាពជាអ្នកដឹកនាំ ។ *(១ ថែស្សាឡូនិក ៥:១២-១៣)*

ការអនុវត្តភាពជាអ្នកដឹកនាំ ដែលមានសិទ្ធិអំណាចក្នុងក្រុមជំនុំនៅក្នុងតំបន់ ត្រូវតែមានភាពឈ្លាសវៃ។ គួរតែផ្តល់នូវការណែនាំ ការការពារ និង ការកំសាន្តចិត្ត។ ដោយហេតុនោះហើយអ្នកដឹកនាំនៅក្នុងក្រុមជំនុំត្រូវការការអធិស្ឋានរបស់អ្នករាល់គ្នា ស្របតាមបទគម្ពីរ *កូល៉ុស ១:៩-១១ និង ២ ថែស្សាឡូនិក ៣:១* ។ ហេតុអ្វីយើងត្រូវការ ភាពជាអ្នកដឹកនាំ និងសិទ្ធិអំណាចតាមរចនាសម្ព័ន្ធ?

## ៣. កិច្ចការ

"អ្វីដែលខ្ញុំហាក់បីដូចជាធ្វើមិនចេះចប់នោះ គឺការងារ" ស្ត្រីម្នាក់ដែលជាម្តាយបានត្អូញត្អែរដូច្នោះ។ វាមិនមែនដើមហេតុនោះទេ ប៉ុន្តែជាញឹកញាប់ ដោយសារតែអ្នកឯទៀតមិនបានជួយធ្វើការងារគាត់។ *១ កូរិនថូស ១២: ៤-៣១ និង រ៉ូម ១២: ៣-៨* បានលើកឡើងអំពីសមត្ថភាពដែលព្រះប្រទានឱ្យ ដើម្បីកិច្ចការក្រុមជំនុំ និងនៅក្នុងព្រះរាជរបស់ព្រះជាម្ចាស់។ កិច្ចការខ្លះទាំងនេះ គឺជាការអនុវត្តជាក់ស្តែង ហើយក៏មានកិច្ចការផ្សេងទៀត បើទោះជាចាំបាច់ក៏ដោយ ក៏មិនសូវមានជាការអនុវត្តចេញនោះទេ។ ទាំងអស់សុទ្ធតែសំខាន់។
សូមចែកចាយជាមួយគ្រិស្តបរិស័ទ ឬគ្រូគង្វាលរបស់លោកអ្នកអំពីកិច្ចការណាមួយដែលលោកអ្នកអាចធ្វើបាន នៅក្នុងគ្រួសារនៃក្រុមជំនុំ ឬនៅក្នុងសហគមន៍ ។ សូមកុំយឺតយ៉ាវនៅក្នុងការបោះជំហាននោះឡើយ!



លោកអ្នកអាចជួយផង និងអាចរកឃើញពីភាពពេញលេញនៅក្នុងពេលដែលធ្វើកិច្ចការនោះផងបានដែរ។

តើលោកអ្នកគិតថា អ្វីដែលលោកអ្នកអាចធ្វើបានល្អបំផុត?

តើអ្វីដែលលោកអ្នកចូលចិត្តធ្វើជាងគេបំផុត?

## ៤. ការធ្វើបន្ទាល់

ធ្វើការប្តេជ្ញាចិត្ត ចូលរួមក្នុងក្រុមជំនុំមួយ ធ្វើជាទីបន្ទាល់ដ៏ល្អម្នាក់។ ឪពុកម្តាយ និងកូនៗខ្លះ មិនសូវចេះផ្សព្វផ្សាយនូវអ្វីដែលល្អពីក្រុមគ្រួសារខ្លួនប៉ុន្មានទេ មិនខុសពីគ្រិស្តបរិស័ទមួយចំនួន ជាអកុសលពួកគេក៏បានធ្វើទៅលើក្រុមជំនុំរបស់ពួកគេដូចគ្នានោះដែរ។ ក្រុមជំនុំដែលមានការទាក់ទាញមនុស្សឲ្យចូលមក គឺជាក្រុមជំនុំដែលអ្នកចូលរួមតែងដឹងថា មានព្រះវត្តមានរបស់ព្រះគ្រិស្តគង់នៅក្នុងចំណោមសមាជិកនៃក្រុមជំនុំនោះ ។ ជីវិត ទាក់ទាញជីវិត! ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់ថា អ្នកជឿគួរតែជាកម្មសិទ្ធិរបស់ក្រុមជំនុំណាមួយនៅក្នុងតំបន់ ។ ឧទាហរណ៍៖

*អ្នកជឿទាំងអស់ នៅតែបន្តការជួបជុំគ្នា ។ កិច្ចការ ២:៤៤*
*«កុំឱ្យយើងបោះបង់ទម្លាប់នៃការជួបជុំគ្នា ... ចូរយើងលើកទឹកចិត្តគ្នាទៅវិញ ទៅមក ។» ហេព្រើរ ១០:២៥*

សូមសរសេរចុះនូវទម្លាប់បួនយ៉ាង ដែលគ្រិស្តបរិស័ទដែលទើបតែជឿថ្មីធ្វើនៅក្នុង គម្ពីរកិច្ចការ ២:៤២ ។

១. ________ ២. ________

៣.______________________ ៤. ______________________

## សេចក្តីសន្និដ្ឋាន

គ្មានក្រុមជំនុំក្នុងតំបន់ណា ដែលអាចឈានដល់ភាពល្អឥតខ្ចោះនោះបានឡើយ ដោយសារតែក្រុមជំនុំទាំងនោះមានមនុស្សដូចជាលោកអ្នក ហើយនិងខ្ញុំ។ ប៉ុន្តែ បើនោះជាមានរឿងអ្វីមិនប្រក្រតីកើតឡើងក៏ដោយ សូមកុំឲ្យព្រលឹងវិញ្ញាណលោកអ្នកមានការវង្វេង។ សូមធ្វើការប្តេជ្ញាចិត្តនៅជាប់នឹងក្រុមជំនុំក្នុងតំបន់ ដែលជាក្រុមជំនុំរស់ខាងឯវិញ្ញាណ ហើយព្រះអង្គនឹងកាន់តែមានភាពច្បាស់ឡើងចំពោះលោកអ្នក។ កិច្ចការបំរើរបស់លោកអ្នក ក៏នឹងកាន់តែមានផលផ្លែ។ ជាទូទៅ នៅពេលដែលលោកអ្នកដាក់ការខិតខំប្រឹងប្រែងកាន់តែច្រើនទៅក្នុងក្រុមជំនុំ នោះលោកអ្នកក៏នឹងកាន់តែទទួលបានផលចេញពីការនោះដែរ។ កុំគ្រាន់តែធ្វើជាអ្នកអង្គុយនៅក្នុងព្រះវិហារនោះឡើយ!